មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន ម.ស.ម.ក
# បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍បានទទួលដីកាបង្គាប់ឱ្យចូលខ្លួននៅតុលាការខេត្តព្រះវិហារ

ភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៨

| | |
|---|---|
| *កាលបរិច្ឆេទនៃហេតុការណ៍៖* | *ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨* |
| *ឈ្មោះ៖* | *ប៊ឹក សោភ័ណ, លួត សាំង និងសមាជិកសហគមន៍ឃុំប្រមេរបួនរូប* |
| *ប្រភេទនៃសកម្មជន៖* | *បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនដីធ្លី* |
| *ទីតាំង៖* | *ឃុំប្រមេរ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ* |
| *ប្រភេទនៃការគំរាមកំហែង៖* | *ការបំភិតបំភ័យនិងយាយីតាមរយៈការប្រើប្រាស់បទចោទព្រហ្មទណ្ឌ* |

នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ នគរបាលបាននាំយកដីកាបង្គាប់ឱ្យចូលខ្លួន មកឱ្យលោក ប៊ឹក សោភ័ណ បុគ្គលិកអង្គការពន្លកខ្មែរ ដើម្បីឱ្យលោកចូលខ្លួនមកសាកសួរនៅសាលាដំបូងខេត្តព្រះវិហារនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ពីបទសមគំនិតក្នុងអំពើចាប់ឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់ (មាត្រា២៩ និងមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា)។ យោងតាមព័ត៌មាននៅក្នុងដីកាបង្គាប់ឱ្យចូលខ្លួន បទចោទនេះពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានកើតឡើងកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ នៅក្នុងឃុំប្រមេរ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។ មិនមានព័ត៌មានលម្អិតបន្ថែមទៀត នៅក្នុងដីកាបង្គាប់ឱ្យចូលខ្លួននោះទេ ដែលផ្ទុយពីសិទ្ធិដើម្បីឱ្យលោកសោភ័ណបានដឹងពីបទចោទប្រកាន់ប្រឆាំងរូបគាត់។ នាមត្រកូល និងព័ត៌មានផ្ទាល់ខ្លួនរបស់លោក សោភ័ណ ដែលមាននៅក្នុងដីកាបង្គាប់ឱ្យចូលខ្លួនមិនត្រឹមត្រូវ ជាហេតុនាំឱ្យលោកបដិសេធទទួលដីកានោះ ហើយស្នើឱ្យនគរបាលបញ្ជូនត្រឡប់ទៅតុលាការវិញដើម្បីកែតម្រូវ។ នៅថ្ងៃជាមួយគ្នានោះ លោកលួត សាំង ដែលជាបុគ្គលិកអង្គការពន្លកខ្មែរដូចគ្នាក៏បានទទួលព័ត៌មានថានគរបាលមូលដ្ឋានបាននាំយកដីកាកោះទៅឱ្យរូបលោកផងដែរ។ នៅពេលនោះលោកជាប់បំពេញបេសកកម្មនៅតាមមូលដ្ឋាន ដូច្នេះលោកមិនបានទទួលដីកានោះទេ។ លោកមិនបានដឹងពីបទចោទដែលមាននៅក្នុងដីកានោះទេ។

ពន្លកខ្មែរ គឺជាអង្គការមិនមែនរដ្ឋាភិបាលតូចមួយដែលមានមូលដ្ឋាននៅខេត្តព្រះវិហារធ្វើការដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការពារធនធានធម្មជាតិកម្ពុជា តាមរយៈការពង្រឹងអំណាចដល់ជនងាយរងគ្រោះនិងជនជាតិដើមភាគតិចដើម្បីធានាបាននូវការការពារសិទ្ធិរបស់ពួកគេ។

ក្រៅពីនេះ យ៉ាងហោចណាស់សមាជិកសហគមន៍បួនរូបក្នុងក្រុមជនជាតិដើមគួយនៅក្នុងឃុំប្រមេរបានទទួលដីកានៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ បង្គាប់ឱ្យចូលខ្លួននៅតុលាការខេត្តព្រះវិហារនៅថ្ងៃដូចគ្នាជាមួយលោក សោភ័ណផងដែរ។ ពួកគេត្រូវបានបង្គាប់ឱ្យចូលខ្លួនក្រោមបទចោទចាប់ឃុំឃាំង និងការបង្ខាំង

ដោយខុសច្បាប់ (មាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ) ពាក់ព័ន្ធនឹងអង្គហេតុដែលបានប្រព្រឹត្តនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ នៅក្នុងឃុំប្រមេ។ មានព័ត៌មានថាសមាជិកសហគមន៍ចំនួនដប់នាក់បានទទួលដីកាដូចគ្នានេះ ប៉ុន្តែ ម.ស.ម.ក បានឃើញដីកាតែបួនប៉ុណ្ណោះ។

ចាប់តាំងពីឆ្នាំ២០១២ មក ឃុំប្រមេបានក្លាយជាទីតាំងនៃជម្លោះដីធ្លីពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋានជនជាតិដើមគួយ និងក្រុមហ៊ុនពីរគឺក្រុមហ៊ុនឡានហ្វេង និងក្រុមហ៊ុនរួយហ្វេងដែលទទួលបានដីសម្បទានសេដ្ឋកិច្ចពីរផ្សេងគ្នានៅឆ្នាំ២០១១ ក្នុងគោលបំណងដាំដើមកៅស៊ូ អាកាស្យា និងអំពៅ ដែលមានទីតាំងនៅលើទឹកដីដូនតារបស់សហគមន៍ជនជាតិដើមគួយ។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ គ្រឿងចក្របានមកឈូសឆាយដីស្រែរបស់អ្នកភូមិសម្រាប់ដីសម្បទានសេដ្ឋកិច្ច។ អ្នកភូមិដែលរង់ចាំឱ្យមានការដោះស្រាយជម្លោះដីធ្លីបានបញ្ឈប់គ្រឿងចក្រ ក្នុងគោលបំណងឱ្យមានការយកចិត្តទុកដាក់ពីអាជ្ញាធរ និងក្រុមហ៊ុនដើម្បីបន្តចរចាស្វែងរកដំណោះស្រាយក្នុងជម្លោះដីធ្លី។ ដោយមិនមានការអើពើណាមួយ នៅថ្ងៃទី៣០ ខែធ្នូ អ្នកភូមិបានបង្ខំឱ្យតៃកុងគ្រឿងចក្របើកគ្រឿងចក្រទៅកាន់ឃុំប្រមេរ ដើម្បីទៅជួបនឹងអាជ្ញាធរ។ តៃកុងគ្រឿងចក្រទាំងពីររូបនោះ បានចាកចេញទៅជាមួយនឹងអាជ្ញាធរនៅថ្ងៃដដែលនោះ។ ប៉ុន្តែដោយគ្មានដំណោះស្រាយ សមាជិកសហគមន៍បដិសេធការនាំយកគ្រឿងចក្រទៅវិញ។ គ្រឿងចក្រនេះត្រូវបានរក្សាទុកនៅសាលាឃុំរហូតដល់ ឆ្នាំ២០១៧ ដែលគ្រឿងចក្រទាំងពីរនេះត្រូវបានដកហូតដោយអាជ្ញាធរដើម្បីជាភស្តុតាងក្នុងការបន្តនីតិវិធីបន្ថែមទៀត។

លោក លូត សាំង និងសមាជិកសហគមន៍មួយចំនួនធ្លាប់បានកោះហៅដើម្បីឆ្លើយបំភ្លឺពាក់ព័ន្ធនឹងហេតុការណ៍ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ កាលពីឆ្នាំ២០១៥ ពាក់ព័ន្ធនឹងបទចាប់ឃុំឃាំង និងការបង្ខាំងដោយខុសច្បាប់។ ដោយសារតែមិនមានការវិវត្តណាមួយកើតឡើងតាំងពីពេលនោះមក ពួកគេបានគិតថាសំណុំរឿងនេះត្រូវបានបិទទៅហើយ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋាន អ្នកស្រី សន រ៉ាមណា តាមរយៈ ទូរស័ព្ទលេខ +៨៥៥ (0) ១៧ ៦៥៥ ៥៩១ ឬតាមរយៈអ៊ីម៉ែល** ramanasorn@cchrcambodia.org ។